# PRESS RELEASE

## Seminar for Lawyers on International Criminal Law

The ECCC is pleased to announce the holding of a seminar on International Criminal Law from 26 to 30 March 2007.

The seminar is organised jointly by the Bar Association of the Kingdom of Cambodia, the ECCC and the East West Center, Hawaii, and funded by the British Embassy, Phnom Penh. The seminar is for lawyers with four years or more of experience, and builds on the highly successful training course for young lawyers held last week.

Expert speakers include Professor David Cohen of the Berkeley War Crimes Studies Center, California, Judge Liu Daqun of the International Criminal Tribunal for the Former Yugoslavia and Judge Phillip Rapoza of the East Timor war crimes court.

The course will be essential for lawyers wishing to defend cases at the ECCC. It will focus on the crimes that are likely to be charged and the way that challenges will be made before the Court. The sessions will start at 8 am and finish at 2.30 pm.

Applicants are encouraged to complete the application form available at www.eccc.gov.kh or at the Bar Association offices and return it to the Administration Office of the Bar Association of the Kingdom of Cambodia, No. 10-11, St. 180, Sangkat Boeung Raing, Khan Daun Penh, Phnom Penh by Thursday 22 March at 5 pm for random selection. Successful candidates will be contacted on 23 March with final details of the course.

# សេចក្ដីប្រកាសព័ត៌មាន

## សិក្ខាសាលាស្ដីពីនីតិព្រហ្មទណ្ឌអន្តរជាតិសំរាប់មេធាវី

អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា មានកិត្តិយស់ប្រកាសបើកសិក្ខាសាលាស្ដីពីនីតិព្រហ្មទណ្ឌអន្តរជាតិ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៦ ដល់ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៧ ។

សិក្ខាសាលា ត្រូវបានសហការរៀបចំដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង East West Center នៃរដ្ឋហាវ៉ៃ សហរដ្ឋអាមេរិក ក្រោមការឧបត្ថម្ភមូលថវិកាពីស្ថានទូតអង់គ្លេសប្រចាំនៅកម្ពុជា ។ សិក្ខាសាលាត្រូវបានរៀបចំឡើងសំរាប់មេធាវីដែលមានបទពិសោធន៏ការងាររយៈពេលបួនឆ្នាំ ឬ ច្រើនជាងនេះ ហើយផ្អែក លើវគ្គបណ្ដុះបណ្ដាលប្រកបដោយជោគជ័យខ្ពស់ ដែលត្រូវបានរៀបចំកាលពីសប្ដាហ៏កន្លងទៅ ដល់មេធាវីដែលទើបតែប្រកបវិជ្ជាជីវៈ ។

បើសិនជាសមាជិក-សមាជិកាមេធាវីមានបំណងចូលរួមសិក្ខាសាលានេះ សូមបំពេញបែបបទដែលអាចរកបាននៅគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញ www.eccc.gov.kh ឬនៅការិយាល័យរដ្ឋបាលនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ហើយបញ្ជូនពាក្យសុំចូលរួមសិក្ខាសាលាឱ្យបានមុនម៉ោង ៥ រសៀល ថ្ងៃព្រហស្បតិ៍ ថ្ងៃ ២២ ខែ មិនា ឆ្នាំ២០០៧ ដើម្បីចាប់ឆ្នោតយកកន្លែងសិក្សា ។ បេក្ខជនដែលត្រូវបានជ្រើសរើស នឹងទទួលដំណឹងនៅថ្ងៃទី ២៣ ខែ មិនា ឆ្នាំ០ ២០០៧ ។

**សេចក្តីពិស្តារ**

"គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសូមអញ្ជើញលោក-លោកស្រីចូលរួមសិក្ខាសាលារយៈពេល ៥ថ្ងៃក្រោមវិធានបទស្តីពី "**នីតិព្រហ្មទណ្ឌអន្តរជាតិ**" ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ២៦ ដល់ ថ្ងៃទី ៣០ ខែមីនា ២០០៧ នៅក្រុងភ្នំពេញ ។ សិក្ខាសាលានេះ នឹងឧទ្ទេសនាមដោយអ្នកជំនាញការមកពីមជ្ឈមណ្ឌល East West Center, នៃរដ្ឋហាវ៉ៃ សហរដ្ឋអាមេរិក និង សកលវិទ្យាល័យ**កាលីហ្វូញ៉ា-ប៊ែកឃីលី** ក្រោមការឧបត្ថម្ភមូលនិធិកាពីស្ថានទូតអង់គ្លេសប្រចាំនៅកម្ពុជា ។

គ្រូឧទ្ទេសនាមរបស់សិក្ខាសាលានេះ រួមមានលោកសាស្ត្រាចារ្យ David Cohen មកពីមជ្ឈមណ្ឌលសិក្សាឧក្រិដ្ឋកម្មសង្គ្រាម-**ប៊ែលឃីលី** លោកចៅក្រម Liu Daqun ចៅក្រមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតប្រទេស**យូហ្គោស្លាវី** និង ចៅក្រម Phillip Rapoza អតីតចៅក្រមនៃតុលាការឧក្រិដ្ឋកម្មសង្គ្រាម **ទីម័រខាងកើត** ។

សិក្ខាសាលានេះនឹងផ្តល់នូវសារប្រយោជន៍ចំពោះមេធាវីដែលមានបំណងការពាររឿងក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សិក្ខាសាលានឹងផ្តោតលើឧក្រិដ្ឋកម្មទាំងឡាយដែលនឹងត្រូវចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញ និងការប្រឈមនានាដែលនឹងកើតឡើងនៅក្នុងសាលាក្តីនេះ ។ សិក្ខាសាលាចាប់ផ្តើមនៅម៉ោង ៨ព្រឹក ហើយបញ្ចប់នៅម៉ោង ២ និង ៣០ នាទី រសៀល ។

បើសិនជាអស់លោក-លោកស្រីមានបំណងចង់ចូលរួមសិក្ខាសាលានេះ សូមបំពេញបែបបទដែលអាចរកបាននៅ គេហទំព័រ www.eccc.gov.kh ឬ នៅការិយាល័យរដ្ឋបាលនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នៅអាគារលេខ១០-១១ ផ្លូវលេខ ១៨០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

ដោយទីកន្លែងសិក្សាមានកំណត់ អាទិភាពនឹងត្រូវផ្តល់ជូនសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីរយៈពេលយ៉ាងតិច ៤ឆ្នាំ ឬ យូរជាងនេះ ។

ចាប់ផ្តើមទទួលពាក្យសុំនៅម៉ោង ៥ រសៀល ថ្ងៃពុធទី ២១ ខែ មីនា ២០០៧ ហើយបេក្ខជនដែលត្រូវបានជ្រើសរើសនឹងទទួលការជូនដំណឹងលំអិតអំពីសិក្ខាសាលានៅថ្ងៃទី ២៣ ខែ មីនា ២០០៧ " ។